# ប្រវត្តិរូបបេក្ខជន

ជីវៈប្រវត្តិសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមពិគ្រោះយោបល់ **REDD+** នៅកម្ពុជា

## វិស័យឯកជនៈ

<table>
<tr><td rowspan="3">បេក្ខជន ក<br></td><td>ឈ្មោះៈ ស៊ុម សាគន្ធ</td></tr>
<tr><td>អង្គការៈ ក្រុមហ៊ុនឡៃជីងអេនហ្សីនៀរីង & សូលុយស្យុង</td></tr>
<tr><td>ជីវៈប្រវត្តិៈ លោក សុគន្ធ គឺជានាយកប្រតិបត្តិក្រុមហ៊ុនឡៃជីងអេនជីនៀរីង & សូលុយស្យុង។ គាត់បានធ្វើការខាងថាមពលកកើតឡើងវិញ និងអនាម័យ និងជាទីប្រឹក្សាជំនាញអស់រយៈពេលជាង ៨ ឆ្នាំ។ នៅក្នុងតំណែងថ្មីៗនេះ គាត់គឺជាទីប្រឹក្សាកម្មវិធីមួយនៅក្នុងអង្គការបង្កន់ពិភពលោក ដែល មានមូលដ្ឋាននៅប្រទេសសឹង្ហបូរី និងគ្រប់គ្រងការិយាល័យក្នុងប្រទេសចំនួនបី គឺ កម្ពុជា វៀតណាម និងឥណ្ឌា។ គាត់ក៏ចូលរួមក្នុងក្រុមហ៊ុន ឱយប៉ុង ដែលជាក្រុមហ៊ុនស.រ.អ ពហុជាតិ ក្នុងនាមជា ទីប្រឹក្សាអភិវឌ្ឍន៍ ដែលបង្កើតក្រុមហ៊ុនជំនួញដែលប្រើប្រាស់ទឹកប្រាក់ជាច្រើនរយលានដុល្លាអាមេរិក នៅក្នុងប្រទេសកម្ពុជាផងដែរ។ គាត់មានចំណាប់អារម្មណ៍លើបញ្ហាសង្គម និងធ្វើឲ្យសហគ្រាសសង្គម ដែលជាក្រុមហ៊ុនមានចំណាប់អារម្មណ៍ក្នុងការផ្តល់សេវាដល់ប្រជាជន អ្នកបង្កើតប្លង់ ដែលបង្កើតផលិតផលដែលអាចជាវបាន និងការច្នៃប្រឌិតដែលគាំទ្រដល់ហិរញ្ញិកមកជួបជុំគ្នា ដើម្បីបង្កើនការយល់ដឹងពង្រីកទម្លាប់ល្អ និងបង្កើតទីផ្សារដែលមានប្រសិទ្ធភាព។<br><br>សុគន្ធបានទទួលសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតរដ្ឋបាលធុរកិច្ច និងជាបេក្ខជនថ្នាក់អនុបណ្ឌិតនៅ AEU, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។<br><br>គាត់ជឿថា ស្ថានភាពសេដ្ឋកិច្ច និងជីវភាពរបស់មនុស្សគ្រប់រូបមានលក្ខណៈដោយឡែកពីគ្នា ហើយត្រូវចងចាំប្រការនេះ នៅពេលផ្តល់យោបល់។ គាត់ក៏ជឿថា សេវាបែបបុគ្គលមានសារៈសំខាន់ នៅពេលផ្គូផ្គងអង្គការនោះជាមួយផលិតផល និងសេវាដែលសមស្រប។</td></tr>
</table>

<table>
<tr><td rowspan="3">បេក្ខជន ខ<br></td><td>ឈ្មោះៈ លូ ជូចាង</td></tr>
<tr><td>អង្គការៈ សមាគមឧស្សាហកម្មឈើកម្ពុជា</td></tr>
<tr><td>ជីវប្រវត្តិៈ លោក លូ ជូចាង បានកំពុងពាក់ព័ន្ធនៅក្នុងវិស័យជំនួញព្រៃឈើរយៈពេល ២០ឆ្នាំ មកហើយ។ គាត់ជានាយកចាត់ការទូទៅនៃក្រុមហ៊ុនក្តារបន្ទះចាន់ដាកម្ពុជា MFG.CO. LTD, ចាប់ពីឆ្នាំ ១៩៩៥មក ហើយគាត់ធ្វើការជាប្រធានសមាគមឧស្សាហកម្មឈើកម្ពុជាអស់រយៈពេល ១៣ឆ្នាំ។ ក្នុងនាមជាតំណាងសមាគមឧស្សាហកម្មឈើកម្ពុជា គាត់មានការទទួលខុសត្រូវលើការលើកកំពស់ការប្រើប្រាស់ដោយមាននិរន្តរភាពនូវការទូទាត់សំណងខាងវិស័យព្រៃឈើ។ គាត់មានសញ្ជាតិតៃវ៉ាន់។ គាត់បាន និងកំពុងរស់នៅភ្នំពេញអស់រយៈពេល ២២ ឆ្នាំមកហើយ។ គាត់បានចូលរួមនៅក្នុងសិក្ខាសាលាជាច្រើនអំពីប្រព័ន្ធច្បាប់ដែលទាក់ទងនឹងផលិតផលឈើនៅកម្ពុជា សាធារ ណៈរដ្ឋឡាវ ប្រ៊ុយណេ វៀតណាម ចិន និងម៉ាឡេស៊ី។ លោក លូ មានសញ្ញាប័ត្រគ្រប់គ្រងធុរកិច្ច ពី សកលវិទ្យាល័យជាតិតៃប៉ិ។ គាត់មានមោទនភាពជាអ្នកពាក់ព័ន្ធស្ម័គ្រចិត្តក្នុងការរួមចំណែកក្នុងក្រុមពិគ្រោះយោបល់សម្រាប់ REDD+ និងចូលរួមក្នុង REDD+ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើនៅកម្ពុជា។</td></tr>
</table>

គ្រឹះស្ថានសិក្សាស្រាវជ្រាវ

| បេក្ខជន ក | ឈ្មោះ៖ ងួន ភក្តី |
|---|---|
|  | អង្គភាព៖ សកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| | ជីវប្រវត្តិ៖ លោក ងួន ភក្តី គឺជាអ្នកថ្លែងបាឋកថា និងអ្នកសម្របសម្រួលនៃដេប៉ាតឺម៉ង់សិក្សាអន្តរជាតិនៅ*សកលវិទ្យាល័យភូមិន្ទភ្នំពេញ*។ តួនាទីទាំងនេះបានជួយគាត់មិនត្រឹមតែក្នុងការបង្រៀនថ្នាក់នានាដែលទាក់ទងនឹងបរិស្ថាន ប៉ុន្តែក៏នៅក្នុងការណែនាំដល់និស្សិតកម្ពុជាដ៏វាងវៃនានាផងដែរ។ នៅសកលវិទ្យាល័យភ្លាក ជាកន្លែងដែលបច្ចុប្បន្ននេះ គាត់កំពុងតែសិក្សាថ្នាក់បណ្ឌិត តាមរយៈមូលនិធិគាំទ្រជា*អាហារូបករណ៍ហ្វូលប្រៃរយៈពេល២ឆ្នាំ* គាត់បានស្ម័គ្រចិត្តធ្វើការជាអ្នកជំនួយការស្រាវជ្រាវដល់សាស្ត្រាចារ្យ រ៉ូណល អ៊ីស្មែន ដើម្បីសិក្សាវិទ្យាសាស្ត្រវាស់កាបូន តាមរយៈការប្រើប្រាស់ GIS និង ការអង្កេតពីផ្កាយរណប។ ការស្រាវជ្រាវវិទ្យាសាស្ត្រក្នុងពេលថ្មីៗកន្លងមកនេះអំពី REDD+ អំពីការចូលរួមរបស់អ្នកពាក់ព័ន្ធនានា បានធ្វើឡើងតាមរយៈអត្ថបទ ដែលបានដាក់ជូនសម្រាប់ការចូលរួមនៅក្នុង *កម្មវិធីអ្នកវិទ្យាសាស្ត្រវ័យក្មេងក្នុងរដូវប្រាំងឆ្នាំ ២០១២* ដែលឧបត្ថម្ភដោយ*វិទ្យាស្ថានអន្តរជាតិដើម្បីវិភាគការស្រាវជ្រាវអនុវត្ត* នៅអូទ្រីស។ នៅទីបញ្ចប់ គាត់បានចេញផ្សាយអត្ថបទដែលមានការពិនិត្យនៃក្រុមអ្នកវិទ្យាសាស្ត្រស្តីពីការបង្កើតទម្រង់ប្លង់នៃគម្រោង REDD+ របស់ធនាគារពិភពលោក លើ*វិទ្យាសាស្ត្រនិងគោលនយោបាយបរិស្ថាន* និងការចូលក្នុង Black et al. (2013) *Climate Change: an Encyclopedia of Science and History*។ |

| បេក្ខជន ខ | ឈ្មោះ៖ សៀក សុផាត |
|---|---|
|  | អង្គភាព៖ សកលវិទ្យាល័យភូមិន្ទភ្នំពេញ **(RUPP)** |
| | ជីវប្រវត្តិ៖ បណ្ឌិត សៀក សុផាត គឺជាអ្នកឯកទេសអភិរក្សជីវៈចម្រុះ និងគ្រប់គ្រងធនធានធម្មជាតិដែលមានបទពិសោធន៍ជាង ១៥ឆ្នាំ លើការបង្រៀន និងការស្រាវជ្រាវ និងការវាយតម្លៃកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះនៅកម្ពុជា ជាពិសេស នៅក្នុងតំបន់មេគង្គ តំបន់បឹងទន្លេសាប និងតំបន់ឆ្នេរ។ ក្នុងនាមជាអ្នកផ្តល់បាឋកថាជាន់ខ្ពស់ និងជាអនុប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថាននៅសកលវិទ្យាល័យភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា បណ្ឌិត សៀក សុផាត បានបង្កើតវគ្គបណ្តុះបណ្តាល និងបានសហការជាមួយគម្រោងជាច្រើននៅទូទាំងកម្ពុជា ដើម្បីបង្កើតកម្មវិធីនានាដែលពាក់ព័ន្ធសម្រាប់និស្សិតថ្នាក់សកលវិទ្យាល័យ និងអ្នកជំនាញគ្រប់គ្រងធនធានធម្មជាតិ។ គាត់បានបង្រៀន និងដឹកនាំនិស្សិតក្នុងកម្មវិធីថ្នាក់អនុបណ្ឌិតអភិរក្សជីវៈចម្រុះ និងសិក្សាការអភិវឌ្ឍ នៅ RUPP។ លោកមានជំនាញខាងការស្រាវជ្រាវដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្ស និងវាយតម្លៃជីវៈចម្រុះ និងបានធ្វើការនៅទូទាំងប្រទេសជាមួយអង្គការនិងម្ចាស់ជំនួយជាច្រើន ដែលរួមទាំង Danida, Sida, DFID, CIDA, AusAID, ADB, WB, ICCO, UNDP, FAO, MRC, Oxfam, Henrich Boll Foundation, CDRI, និង NGOs នៅក្នុងស្រុកជាច្រើន។ ការយកចិត្តទុកដាក់និងចំណាប់អារម្មណ៍លើការស្រាវជ្រាវរបស់គាត់គឺការពិនិត្យតាមដានជីវៈចម្រុះតាមបែបផែននៃការចូលរួម ដែលផ្សារភ្ជាប់អន្តរាគមន៍គ្រប់គ្រងបញ្ហា REDD+ ការអភិវឌ្ឍថាមពលវារីអគ្គិសនី និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់មេគង្គ ដោយសង្កត់ធ្ងន់លើការអភិរក្ស និង ការលើកកំពស់របបចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ |

| បេក្ខជន គ | ឈ្មោះ៖ គឹម សុបិន |
|---|---|

| | |
|---|---|
|  | អង្គភាព៖ សកលវិទ្យាល័យភូមិន្ទកសិកម្ម |
| | ជីវប្រវត្តិ៖ លោក សុបិន គឺជាប្រធានមជ្ឈមណ្ឌលសិក្សាកសិកម្ម និងបរិស្ថាន និងអ្នកសម្របសម្រួលកម្មវិធីអនុបណ្ឌិតវិទ្យាសាស្ត្រនៃមហាវិទ្យាល័យថ្នាក់ក្រោយឧត្តមសិក្សានៃសកលវិទ្យាល័យភូមិន្ទកសិកម្ម។ គាត់មានបទពិសោធន៍ស្រាវជ្រាវ និងបង្រៀនច្រើនជាង ១៥ ឆ្នាំ លើការគ្រប់គ្រងធនធានធម្មជាតិ។ គាត់ជាអ្នកសម្របសម្រួលប្រចាំប្រទេសនៃបណ្តាញសកលវិទ្យាល័យខាងផ្នែកអេកូឡូស៊ីតំបន់ដីសើមនៅក្នុងអាងទន្លេមេគង្គ។ គាត់បានធ្វើការជាអ្នកសម្របសម្រួលគម្រោងប្រែប្រួលអាកាសធាតុនៅ RUA និងបានចូលរួមជាអ្នកបណ្តុះបណ្តាលនៅក្នុងកម្មវិធីនានា ដែលទាក់ទងនឹង "វិធីសាស្ត្រស្រាវជ្រាវក្នុងការប៉ាន់ប្រមាណផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំ" និង "តំបន់អេកូឡូស៊ី និងការគ្រប់គ្រងតំបន់ដីសើមក្នុងអាងទន្លេមេគង្គក្រោម"។ គាត់មានសញ្ញាប័ត្រ ថ្នាក់អនុបណ្ឌិតអំពីវិទ្យាសាស្ត្រជីវិត និងបរិស្ថានពីសកលវិទ្យាល័យត្សូគូបា នៃប្រទេសជប៉ុន និងថ្នាក់អនុបណ្ឌិតស្តីពីការគ្រប់គ្រងធនធានធម្មជាតិកកើតឡើងវិញពី RUA ប្រទេសកម្ពុជា។ |

អង្គការមិនមែនរដ្ឋាភិបាល

| | |
|---|---|
| បេក្ខជន ក | លោក វ៉ា មឿង |
|  | អង្គការ៖ ម្លប់បៃតង |
| | ជីវប្រវត្តិ៖ លោក វ៉ាមឿង កើតនៅឆ្នាំ ១៩៥៦ នៅខេត្តព្រៃវែង។ ក្រោយរបបខ្មែរក្រហម ក្នុងចំណោមមនុស្សមួយចំនួនតូចដែលមានការសិក្សាកម្រិតខ្ពស់និងដែលរួចជីវិតពីរបបខ្មែរក្រហម លោក វ៉ា មឿង បានជួយបើកឡើងវិញមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន និងសាលាមធ្យមសិក្សាមួយចំនួននៅខេត្តព្រៃវែង។ គាត់បានបន្តធ្វើការ និងបានក្លាយជានាយកសាលាមធ្យមសិក្សាមួយនៅឆ្នាំ១៩៩០។ នៅឆ្នាំ ១៩៩៦ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលរយៈពេលបីខែនៅប្រទេសម៉ាឡេស៊ី លោក វ៉ា មឿង ត្រូវបានតែងតាំងដោយក្រសួងអប់រំ យុវជន និងកីឡា ឲ្យធ្វើការនៅក្នុងនាយកដ្ឋានផែនការនៃ ក្រសួងនេះ។ នៅឆ្នាំ ១៩៩៨ លោកបានទទួលអាហារូបករណ៍ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជា ជីវៈរយៈពេល ១០ ខែនៅវិទ្យាស្ថានអន្តរជាតិសម្រាប់ការកសាងផែនការអប់រំនៃអង្គការយូណេស្កូ នៅក្រុងប៉ារីស។ នៅឆ្នាំ ២០០២ ក្រោយបម្រើការក្នុងប្រទេសជាមន្ត្រីរដ្ឋាភិបាលបាន ២៣ឆ្នាំ លោក វ៉ា មឿង បានសម្រេចចូលរួមការងារក្នុងអង្គការម្លប់បៃតង ដែលជាអង្គការបរិស្ថានមួយ ក្នុងនាមជានាយកប្រតិបត្តិ។ ចាប់តាំងពីពេលតែងតាំងនេះមក លើក វ៉ា មឿង បានប្រែក្លាយអង្គការម្លប់បៃតង ពីអង្គការតូចមួយ ដែលមានបុគ្គលិកត្រឹមជាងដប់នាក់ មកជាអង្គការមួយដែលល្បីឈ្មោះ និងមានបុគ្គលិកជាង៧០នាក់ និងថវិកាប្រចាំឆ្នាំច្រើនជាង ១លានដុល្លាអាមេរិក។ ដោយមានគម្រោងនៅក្នុងតំបន់នានានៃខេត្តចំនួន ៨ អង្គការម្លប់បៃតងស្ថិតក្នុងចំណោមអង្គការបរិស្ថានធំជាងគេនៅកម្ពុជា។ ក្នុងនាមជានាយកប្រតិបត្តិ ការទទួលខុសត្រូវរបស់លោក វ៉ា មឿង រួមមាន ការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍកម្មវិធី ការកៀងគរមូលនិធិ និងការឆ្លើយឆ្លងជាមួយម្ចាស់ជំនួយ។ |

| | |
|---|---|
| បេក្ខជន ខ | លោក ជា សារិទ្ធ |
|  | អង្គការ៖ អង្គការស្ត្រីដើម្បីសេដ្ឋកិច្ចទំនើប និងការថែទាំ |
| | ជីវប្រវត្តិ៖ លោក ជា សារិទ្ធ បានធ្វើការជាមួយអង្គការនានា ដោយផ្តោតលើការជួយសហគមន៍ដើម្បីបង្កើតបណ្តាញមួយដើម្បីគាំទ្រដល់សហគមន៍ព្រៃឈើ និងអាងទឹកធម្មជាតិធំៗនៅខេត្តព្រៃវែង។ គាត់ពាក់ព័ន្ធនៅក្នុងការកៀងគរសហគមន៍ដើម្បីបង្កើតគណៈកម្មការអភិរក្សព្រៃឈើ និងបឹង ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាពពីព្រៃឈើ និងបឹងនានា ដោយរៀបចំជាអនុក្រឹត្យ ដែលបានទទួលការអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះបញ្ជីបឹងសហគមន៍ និងតំបន់ព្រៃលិចទឹកនៅរដ្ឋបាលជលផល។<br>លោក សារិទ្ធ មានបញ្ចប់ការសិកសាពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច ដែលផ្តោតលើរដ្ឋបាលសាធារណៈ។ |

| | |
|---|---|
| បេក្ខជន គ | ឈ្មោះ៖ ឈិត សំអាត |
|  | អង្គការ៖ វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| | ជីវប្រវត្តិ៖ ឈិត សំអាត គឺជានាយកប្រតិបត្តិនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៦មក និងជាជនកម្ពុជាដំបូងបង្អស់នៅក្នុងតំណែងនេះ ដែលកាលពីមុនកាន់កាប់ដោយបុគ្គលិកបរទេស។ ការទូលខុសត្រូវចំបងរបស់គាត់គឺដឹកនាំ និងគ្រប់គ្រងវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដើម្បីធានាថា អង្គការនេះសម្រេចគោលដៅរបស់ខ្លួន។ គាត់ បាន និងកំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានានៅកម្ពុជាអស់រយៈពេល២១ឆ្នាំមកហើយ។ នៅចុងឆ្នាំ ១៩៩១ គាត់ជាសមាជិកនៃក្រុមមួយដែលបានបង្កើតក្រុមសិទ្ធិមនុស្សកម្ពុជា នៃអង្គការសិទ្ធិមនុស្ស និងអភិវឌ្ឍន៍(អាដហុក) ដែលជាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដំបូងគេនៅកម្ពុជា។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតខាងផ្នែកកសាងផែនការអភិវឌ្ឍន៍តំបន់ និងជនបទពីមហាវិទ្យាល័យបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិនៃវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ក្នុងប្រទេសថៃ។ ក្រោយវិលពីប្រទេសថៃ គាត់បានចូលធ្វើការនៅវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងតំណែងជាអ្នកសម្របសម្រួលគម្រោងកិច្ច |

| | |
|---|---|
| | ការអភិវឌ្ឍន៍ ដែលជាតំណែងមួយគាត់បានបន្តពីឆ្នាំ ១៩៩៩ដល់ ២០០១។<br>បន្ទាប់មក គាត់ត្រូវបានផ្ទេរមកកាន់តំណែងនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលផ្នែកអភិវឌ្ឍន៍ ដែលមានឈ្មោះថា កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍និងសាមគ្គីភាព( ស៊ីដសេ ) ដែលបានប្តូរមកជាអង្គការសកម្មភាពអភិវឌ្ឍន៍និងភាពជាដៃគូ (DPA)។ បន្ទាប់មកគាត់បានចូលរួមនៅក្នុងដំណើរការប្រែក្លាយអង្គការ DPA ឲ្យទៅជាអង្គការក្នុងស្រុកមួយ និងមានបទពិសោធន៍ជាច្រើន អំពីអភិបាលកិច្ចអង្គការមិនមែនរដ្ឋាភិបាល ដោយផ្តល់វគ្គបណ្តុះបណ្តាលដល់អង្គការមិនមែនរដ្ឋាភិបាលនានាអំពីមុខងាររបស់ក្រុមប្រឹក្សានិងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាទាំងនោះនៅក្នុងអភិបាលកិច្ចអង្គការ។ ក្នុងពេលធ្វើការជាមួយអង្គការស៊ីដសេ លោកត្រូវបានជាប់ឆ្នោតជ្រើសតាំង ជាសមាជិកគណៈកម្មាធិការគ្រប់គ្រងវេទិកាអង្គការមិនមែនរដ្ឋាភិបាល និងបានធ្វើការជាតំណាងរងរយៈពេលមួយឆ្នាំ មុននឹងបានក្លាយជានាយកប្រតិបត្តិពីដើមឆ្នាំ ២០០៦មក។ |

| | |
|---|---|
| បេក្ខជន ឃ<br> | ឈ្មោះ៖អាតេរុហ្សាមែន សាណូ |
| | អង្គការសង្គ្រោះផែនដីកម្ពុជា |
| | ជីវប្រវត្តិ៖ លោក អាតេរុហ្សាមែន សាណូ ដែលមានសញ្ជាតិបង់ក្លាដែស បាន និងកំពុងធ្វើការនៅ កម្ពុជាចាប់តាំងពីឆ្នាំ ២០០២មក។ គាត់គឺជាស្ថាបនិកនៃអង្គការសង្គ្រោះផែនដីកម្ពុជា។ គាត់ធ្វើការជាអ្នកសម្របសម្រួលថ្នាក់តំបន់អាស៊ីប៉ូព៌ា និងអាស៊ីអាគ្នេយ៍នៃកិច្ចផ្តួចផ្តើមសមធម៌ ដែលជាបណ្តាញពិភពលោកនៃសកម្មជន និងអ្នកស្រាវជ្រាវដែលធ្វើការលើបញ្ហានានាដែលទាក់ទងនឹងសមភាពសង្គម សេដ្ឋកិច្ច និងនយោបាយចាប់តាំងពីឆ្នាំ ២០០៣មក និងជាអ្នកសម្របសម្រួលប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃបណ្តាញពិភពលោកសម្រាប់កាត់បន្ថយគ្រោះមហន្តរាយ ដែលពិនិត្យតាមដានក្របខ័ណ្ឌសកម្មភាពហ្យូកូតាំងពីឆ្នាំ ២០០៨មក។ គាត់បាននិងកំពុងផ្តល់សេវាបច្ចេកទេស ក្នុងនាមជាអ្នកជំនាញការអន្តរជាតិឲ្យ ADB, ADRRN, EU/DIPECHO, GNDR, UNDP, UNIDO, UNISDR, ធនាគារពិភពលោក។ល។ ដែលគាំទ្រគម្រោងដែលអនុវត្តដោយក្រសួងពាក់ព័ន្ធ ស្ថាប័ន និងអង្គការសង្គមស៊ីវិលនានានៅកម្ពុជា។ គាត់គឺជាសមាជិកជាប់ឆ្នោតនៃបណ្តាញប្រែប្រួលអាកាសធាតុកម្ពុជា ដែលជាសមាជិកសកម្មមួយនៃ ADRRN, បណ្តាញអង្គការសង្គមស៊ីវិល ខាងបរិស្ថាននៅតំបន់មេគង្គ, CDKN, GDN, PCDN, បណ្តាញ GEF NGO, បណ្តាញអ្នកគាំទ្រ GS NGO, ក្របខ័ណ្ឌអ្នកគាំទ្រ NEXUS NGO និងបានចូលរួមនៅក្នុងវេទិកាចំណេះដឹងអន្តរជាតិជាច្រើន។ គាត់ធ្លាប់ជាអ្នកជំនាញការអន្តរជាតិក្នុងការរៀបចំទម្រង់រួមនៃផែនការមេស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុសម្រាប់រាជរដ្ឋាភិបាលកម្ពុជា (PPCR Cambodia/2012), មូលនិធិ CSO (PPCR Cambodia/2012), បានបង្កើតមជ្ឈមណ្ឌលសម្របសម្រួលកិច្ចការបន្ទាន់និង ផែនការត្រៀមបង្ការការរាតត្បាតនៃជម្ងឺសម្រាប់NCDM(2011), បានបង្កើតផែនការយុទ្ធសាស្រ្តតស៊ូមតិ REDD+ សម្រាប់វេទិកាអង្គការមិនមែនរដ្ឋាភិបាល (2012-2015), បានបង្កើតវេទិកាពហុអ្នកពាក់ព័ន្ធកម្ពុជាសម្រាប់ DRR (2011), និងរបាយការណ៍ GAR សម្រាប់កម្ពុជា (2011)។ គាត់ គឺជាអ្នកជំនាញការបច្ចេកទេសមួយរូបនៃគម្រោងដែលគាំទ្រដោយ UNIDO ដែលបានធ្វើឲ្យកម្ពុជាក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ ២០០៥។ គាត់ក៏ជាអ្នកគ្រប់គ្រងគុណភាព ISO 9001 និងអ្នកជំនាញការប្រព័ន្ធបរិស្ថាន ISO 14001 ផងដែរ។ គាត់បានបញ្ចប់ថ្នាក់អនុបណ្ឌិតភូមិសាស្រ្ត និងវិទ្យាសាស្រ្តបរិស្ថាន និងបាន និងកំពុងសិក្សាថ្នាក់បណ្ឌិតអំពីហិរញ្ញប្បទាន ហានិភ័យអាកាសធាតុសម្រាប់បង្កើនភាពធន់របស់សហគមន៍។ |

អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ

<table>
<tr><td rowspan="3">បេក្ខជន ក<br></td><td>ឈ្មោះ៖ ហួ លឹមឈុន</td></tr>
<tr><td>អង្គការ៖ វីនរ៉ុកអន្តរជាតិ</td></tr>
<tr><td>ជីវប្រវត្តិ៖ លោក ហួ លឹមឈុន ជាអ្នកសម្របសម្រួលប្រចាំប្រទេសនៃកម្មវិធីកាត់បន្ថយការបំភាយឧស្ម័នពីព្រៃឈើនៅអាស៊ី (LEAF) នៃអង្គការវីនរ៉ុកអន្តរជាតិនៅក្នុងប្រទេសចំនួន ៦ នៅអាស៊ីអាគ្នេយ៍ ដើម្បីកំណត់អត្តសញ្ញាណវិធីនានាដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចបំផុតក្នុងការគ្រប់គ្រងដីធ្លីនិងព្រៃឈើនៃប្រទេសទាំងនោះ។ ឈុន មានបទពិសោធន៍ច្រើនជាង ២០ឆ្នាំក្នុងការគ្រប់គ្រងព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន ការអភិវឌ្ឍរបរចិញ្ចឹមជីវិតដោយនិរន្តរភាព ការអភិវឌ្ឍសហគមន៍ជនបទ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (REDD+)។<br>ឈុនមានសញ្ញាប័ត្រវិស្វកម្មរុក្ខកម្មមកពីសកលវិទ្យាល័យភូមិន្ទកសិកម្ម នៅភ្នំពេញ (១៩៩០) និងថ្នាក់អនុបណ្ឌិតព្រៃឈើបរិស្ថាន (ត្រូពិក) មកពីមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម និងព្រៃឈើ នៅសកលវិទ្យាល័យវេលខាងជើង ក្រុងបានហ្គោ ចក្រភពអង់គ្លេស (២០០០)។ គាត់បានធ្វើការ នៅនាយកដ្ឋានព្រៃឈើ និងសត្វព្រៃ គណៈកម្មការទន្លេមេគង្គ, DANIDA, UNDP ហើយមុននឹងចូលរួមនៅក្នុងកម្មវិធី LEAF គាត់បានធ្វើការនៅមូលនិធិ William J. Clinton ឬ កិច្ចផ្តួចផ្តើមអាកាសធាតុគ្លីនតុន ក្នុងនាមជាមន្ត្រីសម្របសម្រួលជាតិសម្រាប់កម្ពុជា។ ឈុន ក៏ធ្លាប់បានធ្វើការជាទីប្រឹក្សារយៈពេលខ្លីសម្រាប់ ITTO, វាយតម្លៃលក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់ការគ្រប់គ្រង ព្រៃឈើដោយនិរន្តរជាតិនៅថ្នាក់ជាតិផងដែរ។</td></tr>
</table>

<table>
<tr><td rowspan="3">បេក្ខជន ខ<br></td><td>ឈ្មោះ៖ ហ៊ូ កល្យាណ</td></tr>
<tr><td>អង្គការ៖ RECOFTC</td></tr>
<tr><td>ជីវប្រវត្តិ៖ លោកស្រី ហ៊ូ កល្យាណ មានបទពិសោធន៍ជាក់ស្តែង ១៧ឆ្នាំ លើការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដោយធ្វើការខាងការកសាងសមត្ថភាព និងការបណ្តុះបណ្តាល តាមរយៈ ការរៀបចំឯកសារណែនាំការបណ្តុះបណ្តាល និងចាត់ចែងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដល់ សិក្ខាកាមជាច្រើនមកពីរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន។<br>បទពិសោធន៍របស់លោកស្រី កល្យាណ គ្របដណ្តប់កិច្ចការទូលំទូលាយដូចជា ការគ្រប់គ្រងព្រៃឈើ និងដីធ្លីដោយនិរន្តរភាព របរចិញ្ចឹមជីវិត អភិបាលកិច្ច និងធនធាន/កម្មសិទ្ធិ ការអភិរក្សជីវៈចម្រុះ ដែលរួមទាំង ច្បាប់ និងបទប្បញ្ញត្តិកម្ពុជា និងអន្តរជាតិ ដែលទាក់ទងនឹងការអភិរក្សធម្មជាតិ។ ជំនាញរបស់គាត់ក៏រួមបញ្ចូល ការបង្កើតឯកសារណែនាំសម្រាប់ការវាយតម្លៃតម្រូវការកសាងសមត្ថភាព និងការបណ្តុះបណ្តាល និងឯកសារបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុជាភាសាខ្មែរផងដែរ។ លោកស្រីកល្យាណ បានផ្តល់ និងសម្របសម្រួលការបណ្តុះបណ្តាលខាងលើដល់អ្នកពាក់ព័ន្ធនានាជាច្រើន។ ទាក់ទងនឹង REDD+ លោកស្រីកល្យាណ បានចូលរួមយ៉ាងសកម្មនៅក្នុងការប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលានានាស្តីពីការគាំទ្រដល់ការពិភាក្សា និងការចែករម្លែកបទពិសោធន៍ និងកង្វល់នានាអំពី REDD និងការកសាងផែនទីបង្ហាញផ្លូវ REDD+ និងការអនុវត្តផែនទីនេះនៅកម្ពុជា។ ប្រការសំខាន់ជាងនេះទៀត លោកស្រីកល្យាណត្រូវបានអញ្ជើញ និងបានចូលរួមនៅក្នុងការរៀបចំសេចក្តីព្រាង ដំណើរការការរៀបចំ និងកសាងផែនទីបង្ហាញផ្លូវ REDD+ សម្រាប់កម្ពុជា ក្នុងនាមជាសមាជិកសង្កេតការណ៍នៃក្រុមការងារបណ្តោះអាសន្ន REDD នៅថ្នាក់ជាតិ ដែលតំណាងឲ្យ RECOFTC។</td></tr>
</table>

| | |
|---|---|
| បេក្ខជន គ | ឈ្មោះ៖ យាង ដូណាល |

| | |
|---|---|
|  | អង្គការៈ រុក្ខជាតិនិងសត្វអន្តរជាតិ **(FFI)** |
| | ជីវប្រវត្តិៈ លោក យាង ដូណល បច្ចុប្បន្នធ្វើការជាទីប្រឹក្សាជាតិគោលនយោបាយ REDD+ នៅ FFI ដែលនៅទីនេះគាត់គាំទ្រដល់ការកសាងគោលនយោបាយ REDD+ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលពង្រឹងតួនាទីរបស់រដ្ឋាភិបាល និងសហគមន៍នៅមូលដ្ឋានក្នុងគម្រោងសហគមន៍ព្រៃឈើ REDD+ នៅខេត្តសៀមរាប ក្រោមកម្មវិធីអាងកាបូនសហគមន៍ REDD+ នៅកម្ពុជា។ គាត់ធ្លាប់ បានធ្វើការជាមន្ត្រីជាន់ខ្ពស់កម្មវិធីកាបូននៃអង្គការផែកកម្ពុជា ដែលនៅទីនោះគាត់ធ្លាប់បានចូលរួមនៅក្នុងការកសាងផែនការ និងការធ្វើសារពើភ័ណ្ឌជីវម៉ាស ការវាយតម្លៃសង្គម ការពិគ្រោះយោបល់អំពីការចែកផលសម្រាប់គម្រោងសហគមន៍ព្រៃឈើ REDD+ នៅឧត្តរមានជ័យ។ បច្ចុប្បន្ននេះ គាត់ចូលរួមនៅក្នុងការពិនិត្យច្បាប់ និងសិទ្ធិកាបូននៅកម្ពុជា ជាមួយសកលវិទ្យាល័យខេមប្រីដ។ ដូណល មានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតចំនួនពីរខាងគោលនយោបាយអភិរក្សព្រៃឈើ និងធម្មជាតិ មកពីសកលវិទ្យាល័យ Wageningen ( ប្រទេសហូឡង់ ) និងសកលវិទ្យាល័យហ្វាំងឡង់ខាងកើត។ |

| | |
|---|---|
| បេក្ខជន ឃ | ឈ្មោះៈ សុភា សុគន្ធណារ៉ុង |
|  | អង្គការៈ សមាគមអភិរក្សសត្វព្រៃ **(WCS)** |
| | ជីវប្រវត្តិៈ លោក សុភា សុគន្ធណារ៉ុង មន្ត្រីជាន់ខ្ពស់កម្មវិធី REDD+ នៃសមាគមអភិរក្សសត្វព្រៃ (WCS)។ គាត់រស់នៅក្រុងភ្នំពេញ និងបានធ្វើការក្នុងវិស័យព្រៃឈើអស់រយៈពេលច្រើនជាង ៦ ឆ្នាំមកហើយ ជាមួយសមាគមអភិរក្សសត្វព្រៃ (WCS), ធ្វើការលើការគ្រប់គ្រងគម្រោងតាមវិស័យ និងមានជំនាញឯកទេសខាងការគ្រប់គ្រងជំនួយឥតសំណង។ គាត់បានធ្វើការជាអ្នកសម្របសម្រួលកម្មវិធីដែលគាំទ្រដល់ការផ្តល់ជំនួយឥតសំណងដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្នុងខេត្តមណ្ឌលគិរី និងការគ្រប់គ្រងផ្ទាល់ជំនួយឥតសំណងខ្នាតតូចដែលផ្តល់ឲ្យអង្គការសហគមន៍ និងសហគមន៍មូលដ្ឋាននៅក្នុងវិស័យព្រៃឈើ និងការកសាងបរេចិញ្ចឹមជីវិតជាមួយ WCS និងអង្គការដទៃទៀត។ បន្ថែមលើការងារចំបងទាំងនេះ គាត់បានធ្វើការសកម្មក្នុងបណ្តាញការងារ និងត្រូវបានជ្រើសរើសជាសមាជិកក្រុមស្នូលនៃអង្គការសង្គមស៊ីវិល REDD+ កម្ពុជា ដែលបានផ្តួចផ្តើមឡើងដោយវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ លោក ណារ៉ុង បានបញ្ចប់ថ្នាក់អនុបណ្ឌិតខាងការអភិវឌ្ឍជនបទមកពីសកលវិទ្យាល័យកម្ពុជា នៅទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា។ |

ក្រុមសង្គមស៊ីវិល

<table>
<tr><td rowspan="3">បេក្ខជន ក<br></td><td>ឈ្មោះ៖ ហុក សាវ</td></tr>
<tr><td>អង្គការ៖ ភូមិខ្ញុំ (MVi)</td></tr>
<tr><td>ជីវប្រវត្តិ៖លោក ហុក សាវ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រខាងវិទ្យាសាស្ត្រកសិកម្ម និង ក្សេត្រសាស្ត្រ នៅសាលាកសិកម្មជាតិព្រែកលៀប (PNSA)។ ការសិក្សារបស់គាត់រួមមាន ការចាត់ ចែងសហគមន៍ វិធីសាស្ត្រស្រាវជ្រាវ ការកសាងផែនការ និងការគ្រប់គ្រងគម្រោង កសិ-ធុរកិច្ច ការដឹកនាំ ការផ្សព្វផ្សាយកសិកម្ម និងការគ្រប់គ្រងធនធានមនុស្ស។ គាត់បានបញ្ចប់ការសិក្សាកុំព្យូទ័រ ខាង word processing, ការប្រាស្រ័យទាក់ទង និងជំនាញទំនាក់ទំនងបុគ្គល និងមេរៀនស្តីពី ការចាត់ចែងសហគមន៍។ តាមរយៈបទពិសោធន៍របស់ខ្លួនខាងការអភិវឌ្ឍសហគមន៍ គាត់បានទទួលចំណេះដឹងទូលំទូលាយខាងការសម្របសម្រួល ការគ្រប់គ្រង និងការចាត់ចែងវគ្គបណ្តុះបណ្តាល ការសម្របសម្រួលសហគមន៍ និងការចាត់ចែង និងការពិនិត្យតាមដានវឌ្ឍនភាពនៃសកម្មភាពគម្រោង។ គាត់មានបទពិសោធន៍ធំទូលាយខាងការលើកថវិកា និងគម្រោងកសាងផែនការ, M&E និងការគ្រប់គ្រង ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងព្រៃឈើ, NRM, ធុរកិច្ច, ការសម្របសម្រួល, ការបង្កើតគម្រោង មីក្រូសហគ្រាស និងការទំនាក់ទំនងទីផ្សារ។<br>ភូមិខ្ញុំ (MVi) គឺជាអង្គការមិនមែនរដ្ឋាភិបាលមិនរកផលកម្រៃមួយ ដែលបានបង្កើតឡើងនៅខែ វិច្ឆិកា ឆ្នាំ ២០០០៦ និងបានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ២០០៧។ អង្គការនេះប្រតិបត្តិការនៅបណ្តាខេត្តភាគឦសាននៃប្រទេសកម្ពុជា ជាពិសេស មណ្ឌលគិរី ក្រចេះ និងស្ទឹងត្រែង។ អង្គការនេះបានក្លាយជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលមានការទទួលស្គាល់អំពីការងារអំពីសិទ្ធិពលរដ្ឋជនជាតិដើម។ អង្គការនេះលើលើកកំពស់ភាពជាម្ចាស់ និងការចូលរួម របស់ជនជាតិដើមភាគតិច ដើម្បីការពារដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ។</td></tr>
</table>

<table>
<tr><td rowspan="3">បេក្ខជន ខ<br></td><td>ឈ្មោះ៖ អាង ជាតិទ្បុំ</td></tr>
<tr><td>អង្គការ៖ ពន្លកខ្មែរ (PKH)</td></tr>
<tr><td>ជីវប្រវត្តិ៖ បទពិសោធន៍ខាងព្រៃឈើរបស់លោកជាតិទ្បុំ គឺទទួលបានពីការសិក្សាពុទ្ធសាសនា ស្តីពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ និងការឡើងកំដៅផែនដី។ គាត់បានចូលរួមជាបុគ្គលិកសង្គមកិច្ចខាងកិច្ចការព្រៃឈើចាប់តាំងពីឆ្នាំ ២០០២មក។ នៅដើមឆ្នាំ ២០០៥ គាត់បានចូលរួមយ៉ាងច្រើននៅក្នុងការងារសហគមន៍ព្រៃឈើក្នុងខេត្តព្រះវិហារ ដោយជជែកជាមួយសហគមន៍មូលដ្ឋាន និងអាជ្ញាធរអំពីកិច្ចការព្រៃឈើសង្គម ជាពិសេស អំពីការគ្រប់គ្រងព្រៃឈើ និងដីធ្លីឲ្យមាននិរន្តរភាព ក៏ដូចជាអំពីការប្រែប្រួលអាកាសធាតុផងដែរ។ ចាប់ពីឆ្នាំ ២០០៨មក គាត់បានចូលរួមនៅក្នុងការអភិវឌ្ឍបរចិញ្ចឹមជីវិតរបស់សហគមន៍ដែលពឹងផ្អែកលើធនធានព្រៃឈើ ជាពិសេស NTFPs និងសហគមន៍អេកូទេសចរណ៍ ដែលជាវិធានមួយសម្រាប់លើកទឹកចិត្តសហគមន៍មូលដ្ឋាន ដើម្បីការពារ និងអភិរក្សព្រៃឈើ ប្រើប្រាស់ធនធានព្រៃឈើឲ្យមាននិរន្តរភាព លើកកំពស់ចំណាងទាក់ ទាងខាងទីផ្សារសម្រាប់សហគមន៍មូលដ្ឋាន និងលើកកំពស់ជំនួញ NTFPs នៅកម្ពុជា ដែលស្របគ្នា ជាមួយគោលនយោបាយរបស់រដ្ឋាភិបាលស្តីពីភូមិមួយ ផលិតផលមួយ។<br>បច្ចុប្បន្ននេះ គាត់ចូលរួមនៅក្នុងការពិគ្រោះយោបល់នៅថ្នាក់ជាតិ និងតំបន់ និងការផ្លោះប្តូរចំណេះដឹងអំពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការពិនិត្យតាមដានគោលការណ៍ណែនាំរបស់ FAO ស្តីពីការអនុវត្តកម្មវិធីសន្តិសុខកម្មសិទ្ធិដីធ្លី។ គាត់ក៏ចូលរួមនៅក្នុងបណ្តាញថ្នាក់តំបន់នៃការពិគ្រោះយោបល់នៅថ្នាក់អនុតំបន់អាស៊ីអាគ្នេយ៍ស្តីពីការអភិវឌ្ឍដើម្បីការវិនិយោគលើកសិកម្ម គោលការណ៍ណែនាំស្ម័គ្រចិត្តអំពីសន្តិសុខកម្មសិទ្ធិដីធ្លី (FAO) និងអាទិភាពនានាដទៃទៀតរបស់សហគមន៍ព្រៃឈើផងដែរ។</td></tr>
</table>

| បេក្ខជន គ | ឈ្មោះ៖ រិទ្ធិ ប៊ុនរឿន |
|---|---|
|  | អង្គភាព៖ អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ **(AFD )** |
| | ជីវប្រវត្តិ៖ លើក រិទ្ធិ ប៊ុនរឿន បច្ចុប្បន្នធ្វើការជានាយកប្រតិបត្តិអង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ (AFD), ដែលជាអង្គការមិនស្វែងរកផលចំណេញមួយ មានការិយាល័យនៅថ្នាក់ខេត្ត និងមិនជាប់ពាក់ព័ន្ធនឹងសាសនា និងគ្មានជាប់និន្នាការបុគ្គល និងគណៈបក្សនយោបាយឡើយ។ អង្គការនេះ ត្រូវបានបង្កើតឡើងនៅខែ ឧសភា ឆ្នាំ ២០០៤ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ក្នុងខែឧសភា ឆ្នាំ ២០០៦។<br>គាត់មានភារៈទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ និងផែនការការងារកម្រិតជាតិ ធ្វើការពិនិត្យតាមដាន និងវាយតម្លៃគម្រោង និងរៀបចំរបាយការណ៍ពាក់ព័ន្ធ។ គាត់ក៏មានភារៈទទួលខុសត្រូវលើកផែនការថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ និងគម្រោងផងដែរ ក៏ដូចជា ចាត់ចែងការប្រជុំប្រចាំខែ រៀបចំផែនការសិក្ខាសាលា និងការចាត់ចែងភស្តុភារផងដែរ។ គាត់ធ្លាប់បានធ្វើការជាមួយអង្គការ និងស្ថាប័ននានា ដែលរួមទាំង មេឌីខាម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSVY), និងដៃគូដើម្បីអភិវឌ្ឍន៍អន្តរជាតិ (PFD)។ |

| បេក្ខជន ឃ | ឈ្មោះ៖ ស្មើន បុរីរ័ត្ន |
|---|---|
|  | អង្គភាព៖ សមាគមអភិវឌ្ឍន៍កុមារ **(CDA)** |
| | ជីវប្រវត្តិ៖ លោក ស្មើន បុរីរ័ត្ន គឺជានាយកប្រតិបត្តិរងនៃអង្គការ CDA។ កាលពីដើម គាត់គឺជាកសិករ និងជាជនជាតិដើមកួយ។ គាត់បានធ្វើការខាងព្រៃឈើអស់រយៈពេលជាង ១៥ឆ្នាំមកហើយ និងជាមួយគម្រោងសាកល្បង REDD+ នៅខេត្តឧត្តរមានជ័យ អស់រយៈពេលជាង ៦ឆ្នាំ។ គាត់ធ្លាប់ធ្វើជាទីប្រឹក្សាក្នុងគម្រោងធនាគារពិភពលោកខាងការពិគ្រោះយោបល់ជាមួយសហគមន៍អំពី REDD+ នៅកម្ពុជា។ គាត់បានធ្វើការក្នុងខេត្តច្រើនជាង ១១ និងនៅថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ដែលរួមទាំង ជាសមាជិកនៃបណ្តាញដីធ្លី និងព្រៃឈើនៅថ្នាក់ជាតិផងដែរ ដែលបានផ្តោតលើការអនុវត្ត ការពិគ្រោះយោបល់ និងគោលនយោបាយ។ ការងាររបស់គាត់ក៏បានផ្តល់ឲ្យគាត់នូវឱកាសដើម្បីធ្វើការដោយផ្ទាល់ជាមួយសហគមន៍ទន់ខ្សោយ និងជនជាតិដើមភាគតិចផងដែរលើការអភិវឌ្ឍសហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិ សិទ្ធិមនុស្ស និងកម្មវិធីកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលនៅពេលចុងក្រោយនេះបានផ្តោតលើការអនុវត្តក្របខ័ណ្ឌ REDD+ នៅឧត្តរមានជ័យ និងកម្មវិធីព្រៃឈើជាតិ (NFP) ។ គាត់បានបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលអំពី REDD+ និងវគ្គបណ្តុះបណ្តាលគ្រូបង្គោលនៅប្រទេសនេប៉ាល់ ស្តីពីការពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងកម្មវិធីព្រៃឈើជាតិ។ បុរីរ័ត្នមានសញ្ញាប័ត្រថ្នាក់អនុបណ្ឌិតរដ្ឋបាលធុរកិច្ច និងថ្នាក់បរិញ្ញាប័ត្រសេដ្ឋកិច្ចកសិកម្ម និងការអភិវឌ្ឍជនបទ។ |

| បេក្ខជន ង | ឈ្មោះ៖ គិន ស៊ឹម |
|---|---|
|  | អង្គភាព៖ សមាគមដើម្បីអភិវឌ្ឍន៍ភូមិកំណើត |
| | ជីវប្រវត្តិ៖ លោក គិន ស៊ឹម ជានាយកប្រតិបត្តិនៃអង្គការ AFHOD, ដែលជួយជនជាតិខ្មែរដែលមានប្រាក់ចំណូលទាប (ដែលមានប្រាក់ចំណូលទាបជាង ១ដុល្លាអាមេរិក្នុងមួយថ្ងៃ) ក្នុងការលើកកំពស់សន្តិសុខស្បៀង និងធ្វើការស្រាវជ្រាវខាងទំនាក់ទំនងទីផ្សារ។<br>កាលពី២៥ឆ្នាំកន្លងមកនេះ គាត់បានធ្វើការក្នុងនាយកដ្ឋានសេវាកម្មសង្គម និងសុខភាព នៅរដ្ឋវ៉ាស៊ីនតោន ស.រ.អា ក្នុងនាមជាបុគ្គលិកសង្គមកិច្ច ដែលផ្តល់ជំនួយហិរញ្ញវត្ថុ និងឱសថ និងកម្មវិធីស្បៀង និងការប្រឹក្សាសម្រាប់ជនពិការដើម្បីអាចពឹងផ្អែកលើខ្លួនឯងបាន។<br>គាត់មានចំណាប់អារម្មណ៍ជាពិសេស លើការសិក្សាអំពីវិធីការពារព្រៃឈើ កសាងផែនការកម្មវិធី បរិស្ថានព្រៃឈើ និងអំពីការប្រែប្រួលអាកាសធាតុ។ |

បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ

<table>
<tr><td rowspan="3">បេក្ខជន ៥<br>(គ្មានអ៊ីម៉ែល)</td><td>ឈ្មោះ៖ គាន ហ៊ាន</td></tr>
<tr><td>អង្គភាព៖ សហគមន៍តំបន់ការពារធម្មជាតិភ្នំប្រុស</td></tr>
<tr><td>ជីវប្រវត្តិ៖ លោក គាន ហ៊ាន បាន និងកំពុងធ្វើការជាប្រធានក្រុមសហគមន៍តំបន់ការពារធម្មជាតិ ភ្នំប្រុស តាំងពីឆ្នាំ ២០១១មក ដោយមានការគាំទ្រពី AFD និងការសម្របសម្រួលពីមន្ទីរបរិស្ថានកំពង់ធំ និងដែនជម្រកសត្វព្រៃបឹងពែរ ក្នុងខេត្តកំពង់ធំ។ គាត់បានចូលរួមការប្រជុំ និងសិក្ខាសាលានានាស្តីពីច្បាប់ការពារធម្មជាតិ កម្មវិធីវិនិយោគឃុំ និងការកសាងផែនការអភិវឌ្ឍន៍ឃុំ និងស្រុក។<br>សហគមន៍តំបន់ការពារធម្មជាតិភ្នំប្រុស ត្រូវបានបង្កើតឡើងនៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១១ ក្នុងស្រុកប្រាសាទបាឡាំង ខេត្តកំពង់ធំ។ សហគមន៍នេះមាន ៩៦គ្រួសារ និងមានសមាជិក ៥ នាក់នៅក្នុងគណៈកម្មការសហគមន៍ ដែលបានការទទួលស្គាល់ពីប្រធានឃុំ នៅខែ វិច្ឆិកា ឆ្នាំ ២០១១ និងក្រសួងបរិស្ថាននៅខែ មិថុនា ឆ្នាំ ២០១២។ សហគមន៍តំបន់ការពារធម្មជាតិនេះមានផ្ទៃដីសរុប ២៥៥០ហ.ត។</td></tr>
</table>

<table>
<tr><td rowspan="3">បេក្ខជន ៥<br><br></td><td>ឈ្មោះ៖ ព្រុំ សារ៉ាត</td></tr>
<tr><td>អង្គភាព៖ សហគមន៍តំបន់ការពារធម្មជាតិដែនជម្រកសត្វព្រៃភ្នំសំកុះ</td></tr>
<tr><td>ជីវប្រវត្តិ៖ លោក ព្រុំ សារ៉ាត ជាមេដឹកនាំសហគមន៍តំបន់ការពារធម្មជាតិនៃដែនជម្រកសត្វព្រៃភ្នំសំកុះ នៅសំឡូត ខេត្តបាត់ដំបង។ គាត់មានបទពិសោធន៍រយៈពេលច្រើនជាង ៧ ឆ្នាំ ខាងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។ គាត់បានរួមចំណែកក្នុងការកៀងគរធនធានដើម្បីគាំទ្រដល់សកម្មភាពនានានៃសហគមន៍តំបន់ការពារធម្មជាតិនេះ និងជួយសម្រួលដល់ដំណើរការខាងផ្លូវច្បាប់នៃ CPA ផងដែរ។ លើសពីនេះ គាត់មានការសម្របសម្រួលល្អជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដែលធ្វើការក្នុងដែនជម្រកសត្វព្រៃភ្នំសំកុះ។</td></tr>
</table>

បណ្តាញសហគមន៍ព្រៃឈើ

<table>
<tr><td rowspan="3">បេក្ខជន ក<br></td><td>ឈ្មោះ៖ សា ថ្លៃ</td></tr>
<tr><td>អង្គភាព៖ សហគមន៍ព្រៃឈើឧត្តរមានជ័យ</td></tr>
<tr><td>ជីវប្រវត្តិ៖ លោក សា ថ្លៃ គឺជាប្រធានបណ្តាញសហគមន៍ព្រៃឈើនៅខេត្តឧត្តរមានជ័យ ដែលនេះជាតំណែងដែលគាត់បានកាន់កាប់តាំងពីឆ្នាំ ២០០៥មក។ កាលពីដំបូងគាត់ជាអ្នកការពារព្រៃឈើ និងកសិករ និងបានធ្វើការនៅក្នុងសហគមន៍ព្រៃឈើចំនួន ១៣ នៅខេត្តឧត្តរមានជ័យតាំងពីឆ្នាំ ២០០៤មក ដែលរួមមាន ៦ ឆ្នាំ ធ្វើការក្នុងគម្រោងសាកល្បង REDD+ នៅខេត្តឧត្តរមានជ័យ ដែលរួមចំណែកកាត់បន្ថយកត្តាដែលនាំឲ្យបាត់បង់ព្រៃឈើ និងរេចរឹលព្រៃឈើ និងផ្តល់ការកសាងសមត្ថភាពដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។ គាត់គឺជាសកម្មជនក្នុងការបង្កើនការ យល់ដឹងក្នុងចំណោមសមាជិកសហគមន៍អំពីឱកាស ដើម្បីធ្វើការតស៊ូមតិ និងដោះស្រាយបញ្ហាសំខាន់ៗ និងការប្រឈមនានា ដើម្បីកែលម្អការគ្រប់គ្រងធនធានព្រៃឈើ។ គាត់បានផ្តល់ការកសាងសមត្ថភាពដល់ក្រុមសហគមន៍ព្រៃឈើច្រើនជាង ២៨ អំពីការចាត់ចែងឯកសារច្បាប់នៅក្នុងខេត្តព្រះវិហារ ហើយគាត់ក៏បានចូលរួមយ៉ាងសកម្មនៅក្នុងបណ្តាញដីធ្លី និងព្រៃឈើថ្នាក់ជាតិផងដែរ។</td></tr>
</table>

<table>
<tr><td rowspan="3">បេក្ខជន ខ<br></td><td>ឈ្មោះ៖ ម៉ៅ ង៉ា</td></tr>
<tr><td>អង្គភាព: សហគមន៍ព្រៃឈើត្បែងលិច</td></tr>
<tr><td>ជីវប្រវត្តិ៖ លោក ម៉ៅ ង៉ា គឺជាមេដឹកនាំគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ នៅត្បែងលិច ក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប។ គាត់បានបទពិសោធន៍ច្រើនជាង ១០ឆ្នាំ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ។ នៅក្រោមការគ្រប់គ្រងរបស់គាត់ សហគមន៍ព្រៃឈើត្បែងលិចត្រូវបានចាត់ជា សហគមន៍ព្រៃឈើជោគជ័យបំផុតមួយនៅខេត្តសៀមរាប ដោយមានសមាជិកសហគមន៍ចូលរួមយ៉ាងសកម្មនៅក្នុងការល្បាតព្រៃឈើ ការដាំដើមឈើ និងការធ្វើសុរុក្ខាកម្មព្រៃឈើ។</td></tr>
</table>

បណ្តាញសហគមន៍នេសាទ

| | |
|---|---|
| បេក្ខជន ក | ឈ្មោះ៖ ឡុង សុចែត |
| | អង្គការ៖ សម្ព័ន្ធភាពប្រជានេសាទកម្ពុជា **(CCF)** |
| | ជីវប្រវត្តិ៖ លោក ឡុង សុចែត បាន និងកំពុងធ្វើការនៅសម្ព័ន្ធភាពប្រជានេសាទកម្ពុជា ក្នុងនាមជាប្រធានសម្ព័ន្ធភាពនេះតាំងពីឆ្នាំ ២០០៥មក។ គាត់ធ្លាប់ជាសមាជិកគណៈកម្មការនៃសហគមន៍ នេសាទអស់រយៈពេលជាង ១០ឆ្នាំ និងជាគ្រូបង្រៀនបន្ថែមអស់រយៈពេលជាង ៩ឆ្នាំ។<br><br>សម្ព័ន្ធភាពប្រជានេសាទបានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ២០០៥ និងបានចងជាបណ្តាញការងារជាមួយប្រជានេសាទ និងសហគមន៍នេសាទនៅកម្ពុជា (តំបន់សមុទ្រ ទន្លេមេគង្គ និងបឹងទន្លេសាប)។ គាត់មានតួនាទីសម្របសម្រួល និងធ្វើការជាមួយអង្គការ FACT។ |

| | |
|---|---|
| បេក្ខជន ខ<br> | ឈ្មោះ៖ សៅ ជាង |
| | អង្គភាព៖ សហគមន៍នេសាទព្រៃខ្មៅ |
| | ជីវប្រវត្តិ៖ លោក សៅ ជាង ធ្វើការក្នុងសហគមន៍នេសាទព្រៃខ្មៅតាំងពីឆ្នាំ ២០០៤មក។ គាត់បានចាប់ផ្តើមជាអនុប្រធាន និងមួយឆ្នាំក្រោយមកត្រូវបានតែងតាំងជាប្រធានសហគមន៍នេសាទនោះ។ គាត់មានបទពិសោធន៍រយៈពេលវែងក្នុងការងារសហគមន៍ និងសម្របសម្រួលកិច្ចការជាច្រើន តាំងពីគណៈកម្មការនេះបានបង្កើតឡើង។ លើសពីនេះ គាត់ក៏បានជួយអន្តរាគមន៍ប្រឆាំងសកម្មភាពល្មើសច្បាប់នានានៅក្នុងសហគមន៍នេះផងដែរ។ |